ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០២១/២៤ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេស ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ សម្រាប់ឆ្នាំ២០២៤ (Special EPS-TOPIK) តាមប្រព័ន្ធកុំព្យូទ័រ

យោងតាមលិខិតលេខ EPS-1134 របស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស (HRD-Korea) នៃក្រសួងមុខរបរ និងការងាររបស់សាធារណរដ្ឋកូរ៉េ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (គ.ប.ប.ព.ប) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនអំពីការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេស ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ សម្រាប់ឆ្នាំ២០២៤ (Special EPS-TOPIK) តាមប្រព័ន្ធកុំព្យូទ័រ សម្រាប់វិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

## ១-លក្ខខណ្ឌដើម្បីដាក់ពាក្យប្រឡង

មានតែបេក្ខជនដែលមានឈ្មោះក្នុង "បញ្ជីឈ្មោះបេក្ខជនដែលមានសិទ្ធិដាក់ពាក្យសុំសិទ្ធិប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេស ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ សម្រាប់ឆ្នាំ២០២៤ (Special EPS-TOPIK) តាមប្រព័ន្ធកុំព្យូទ័រ" ដែលនឹងបិទផ្សាយនៅថ្ងៃព្រហស្បតិ៍ ទី០១ ខែសីហា ឆ្នាំ២០២៤ នៅលើគេហទំព័ររបស់ គ.ប.ប.ព.ប (www.mtosb.gov.kh) ទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ គ.ប.ប.ព.ប (www.facebook.com/mtosbcambodia) និងតេលេក្រាមផ្លូវការ EPS-Cambodia (https://t.me/epscambodia) ហើយបំពេញតាមលក្ខខណ្ឌដូចខាងក្រោមប៉ុណ្ណោះ ដែលអាចដាក់ពាក្យសុំសិទ្ធិប្រឡងបាន៖

- បេក្ខជនដែលបានបន្តកិច្ចសន្យាការងារ និងចាកចេញពីសាធារណរដ្ឋកូរ៉េ មុនថ្ងៃផុតកំណត់កិច្ចសន្យាការងារដោយស្របច្បាប់ (ត្រលប់មកកម្ពុជាក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១០)
- បេក្ខជនដែលមានអាយុចាប់ពី១៨ ដល់៣៩ឆ្នាំ (កើតចន្លោះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៨៤ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦)
- បេក្ខជនដែលមិនធ្លាប់ធ្វើការខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ និងមិនដែលត្រូវបានបណ្តេញចេញពីសាធារណរដ្ឋកូរ៉េ
- បេក្ខជនដែលមិនធ្លាប់ជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋធ្ងន់ធ្ងរ
- បេក្ខជនដែលមិនត្រូវបានហាមឃាត់ឱ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- បេក្ខជនដែលមិនធ្លាប់ស្នាក់នៅ និងធ្វើការនៅសាធារណរដ្ឋកូរ៉េលើសពី ០៥ឆ្នាំ (រួមបញ្ចូលទាំងប្រភេទទិដ្ឋាការ E-9 និងE-10) លើកលែងការបន្តដោយស្វ័យប្រវត្តិក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## ២-ការចុះឈ្មោះប្រឡង

- ចាប់ពីថ្ងៃចន្ទ ទី១៩ រហូតដល់ថ្ងៃព្រហស្បតិ៍ ទី២២ ខែសីហា ឆ្នាំ២០២៤
- បេក្ខជនត្រូវចុះឈ្មោះតាម កម្មវិធី EPS-TOPIK Cambodia ដែលអាចទាញយកបានពី Play Store ឬគេហទំព័រ www.eps.mtosb.gov.kh និងគ្មានការកំណត់ចំនួនបេក្ខជនចុះឈ្មោះប្រឡងឡើយ
- ប្រសិនបើបេក្ខជនបានបញ្ចប់**វគ្គសិក្សាភាសាកូរ៉េ TOPIK កម្រិត៣ ឬវគ្គបណ្តុះបណ្តាលជំនាញការងារ និង បង្កើតអាជីវកម្ម** ក្នុងកម្មវិធី Resettlement Support Training សូមទំនាក់ទំនងមកកាន់តេលេក្រាម ០១២ ២៥៣ ៥៥៥ ដើម្បីទទួលបានអត្ថប្រយោជន៍បន្ថែម
- **តម្លៃសុំសិទ្ធិប្រឡងជូនទៅអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ (HRD-Korea) នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ៖ ២៨USD (ម្ភៃប្រាំបីដុល្លារអាម៉េរិក)**
- ឯកសារចាំបាច់សម្រាប់ Upload ក្នុងកម្មវិធី៖
  - លិខិតឆ្លងដែន
  - រូបថតពណ៌ធម្មជាតិដែលមិនមានការតុបតែង ទំហំ ៣.៥ x ៤.៥ សង់ទីម៉ែត្រ (ផ្ទៃខាងក្រោយពណ៌ស)។

## ៣-កាលបរិច្ឆេទប្រឡង

- ការបិទឈ្មោះប្រឡង ៖ ថ្ងៃពុធ ទី២៨ខែសីហា ឆ្នាំ២០២៤ នៅលើគេហទំព័ររបស់ គ.ប.ប.ព.ប www.mtosb.gov.kh ទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ គ.ប.ប.ព.ប (www.facebook.com/mtosbcambodia) និងតេលេក្រាមផ្លូវការ EPS-Cambodia (https://t.me/epscambodia)
- មណ្ឌលប្រឡង ៖ ជាន់ទី៤ អគារមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ ស្ថិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- កាលបរិច្ឆេទប្រឡង ៖ ចាប់ពីថ្ងៃពុធ ទី៤ ខែកញ្ញា ឆ្នាំ២០២៤ តទៅ ដោយក្នុងមួយថ្ងៃមានការប្រឡង ចំនួន ០៤វេន៖

| **វេនប្រឡង** | **ការពន្យល់ណែនាំពីរបៀបប្រឡង** | **រយៈពេលនៃការប្រឡង** | |
|---|---|---|---|
| | | **វិញ្ញាសាអាន(២៥នាទី)** | **វិញ្ញាសាស្តាប់(២៥នាទី)** |
| វេនទី១ | ០៨:៣០~០៩:៣០ | ០៩:៣០~០៩:៥៥ | ០៩:៥៥~១០:២០ |
| វេនទី២ | ១០:០០~១១:០០ | ១១:០០~១១:២៥ | ១១:២៥~១១:៥០ |
| វេនទី៣ | ១២:៣០~១៣:៣០ | ១៣:៣០~១៣:៥៥ | ១៣:៥៥~១៤:២០ |
| វេនទី៤ | ១៤:០០~១៥:០០ | ១៥:០០~១៥:២៥ | ១៥:២៥~១៥:៥០ |

- បេក្ខជនត្រូវចូលក្នុងបន្ទប់ប្រឡងឱ្យបានមុនម៉ោងពន្យល់ណែនាំពីរបៀបប្រឡង។ កាលវិភាគប្រឡងអាចមានការប្រែប្រួលតាមការចាំបាច់របស់អង្គភាព HRD-Korea។

## ៤-ចំនួនបេក្ខជនប្រឡងជាប់

- ចំនួនបេក្ខជនដែលប្រឡងជាប់នឹងផ្សព្វផ្សាយនៅពេលក្រោយ ដោយជ្រើសរើសបេក្ខជនតាមលំដាប់ពិន្ទុពីខ្ពស់មកទាបដោយមិនគិតពីវិស័យការងារ
- ការកំណត់ពិន្ទុ គឺធ្វើឡើងដោយអង្គភាព HRD-Korea។

## ៥-វិញ្ញាសាប្រឡង

- វិញ្ញាសាអានមានចំនួន ២០សំណួរ (២៥នាទី) និងវិញ្ញាសាស្តាប់មានចំនួន ២០សំណួរ (២៥នាទី)។ វិញ្ញាសាទាំងពីរនឹងត្រូវអនុវត្តជាបន្តបន្ទាប់ដោយគ្មានការឈប់សម្រាកឡើយ
- ឯកសារដែលត្រូវយកមកជាមួយនៅថ្ងៃប្រឡង៖
  - លិខិតឆ្លងដែនច្បាប់ដើម ដូចគ្នាទៅនឹងពេលដាក់ពាក្យសុំសិទ្ធិប្រឡង (ក្នុងករណីមិនបានយកមកជាមួយ នោះអង្គភាព HRD-Korea មិនអនុញ្ញាតឱ្យប្រឡងជាដាច់ខាត និងមិនអាចលើកកាលបរិច្ឆេទប្រឡងបានឡើយ)
  - អត្តសញ្ញាណប័ណ្ណច្បាប់ដើម មិនអាចប្រើប្រាស់ក្នុងការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេស ជំនួសលិខិតឆ្លងដែនច្បាប់ដើមបានឡើយ។

## ៦-ការប្រកាសលទ្ធផលប្រឡង

- លទ្ធផលប្រឡងនឹងប្រកាសជូននៅថ្ងៃសុក្រ ទី១៣ ខែកញ្ញា ឆ្នាំ២០២៤ ផ្សាយលើទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ គ.ប.ប.ព.ប (www.facebook.com/mtosbcambodia) គេហទំព័ររបស់ គ.ប.ប.ព.ប (www.mtosb.gov.kh) តេលេក្រាមផ្លូវការ EPS-Cambodia (https://t.me/epscambodia) និងគេហទំព័រ (www.eps.go.kr) របស់អង្គភាព HRD-Korea
- សុពលភាពនៃលទ្ធផលប្រឡងមានរយៈពេលចំនួន ០២ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសលទ្ធផល។

## ៧-ព័ត៌មានផ្សេងៗ

- បេក្ខជនដែលប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េពិសេសនេះ នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា ការចុះឈ្មោះ សុំស្វែងរកការងារធ្វើដោយប្រើរយៈពេលខ្លី និងមិនចាំបាច់ទទួលការបណ្តុះបណ្តាលមុនចេញដំណើរ
- នៅថ្ងៃប្រឡងមិនអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡងនូវទូរស័ព្ទដៃ សំណៅឯកសារ វចនានុក្រមអេឡិចត្រូនិច និងឧបករណ៍អេឡិចត្រូនិចផ្សេងៗទៀតដែលអាចប្រើប្រាស់ក្នុងការលួចបន្លំ។ ក្នុងករណីដែលរកឃើញថាមានការលួចបន្លំ នោះការប្រឡងតេស្តនឹងចាត់ទុកជាមោឃៈ និងត្រូវដកសិទ្ធិប្រឡងរយៈពេល ០៤ឆ្នាំ
- ប្រសិនបើព័ត៌មានផ្ទាល់ខ្លួន (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) នៅលើលិខិតឆ្លងដែន មិនដូចគ្នានឹងព័ត៌មាននៅលើពាក្យសុំសិទ្ធិប្រឡងទេ នោះបេក្ខជននឹងមិនត្រូវបានចុះឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកសុំស្វែងរកការងារធ្វើក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS ក៏ដូចជាការបញ្ជូនទៅសាធារណរដ្ឋកូរ៉េឡើយ។ បេក្ខជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហាដែលបណ្តាលមកពីភាពខុសគ្នានៃព័ត៌មានទាំងនោះ

☞ ដើម្បីបង្កើនប្រសិទ្ធភាពនៃការជ្រើសរើសពលករដែលមានចំណេះដឹងភាសាកូរ៉េ ឱ្យទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS អង្គភាព HRD-Korea នឹងធ្វើការផ្លាស់ប្តូរសំណួរនៃ

ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ (EPS-TOPIK) ពីការដកស្រង់សំណួរពីសៀវភៅកម្រងសំណួរចម្លើយ ជំនួសដោយការដកស្រង់ចេញពី "សៀវភៅស្តង់ដារសម្រាប់ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ EPS-TOPIK (The Standard Textbook for EPS-TOPIK)" ដែលមានតែមេរៀនសុទ្ធ។ បេក្ខជនអាចទាញយកជាសៀវភៅមេរៀន (PDF File) និងមេរៀនជាសម្លេង (MP3) បាន តាមរយៈគេហទំព័រ www.epstopik.hrdkorea.or.kr។

- ការប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េពិសេស មិនមានន័យថាបានប្រឡងជាប់ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េឡើយ
- បេក្ខជនដែលធ្លាក់តេស្តសុខភាព ឬធ្លាប់ស្នាក់នៅដោយខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ មិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំស្វែងរកការងារធ្វើនៅសាធារណរដ្ឋកូរ៉េឡើយ បើទោះបីជាបានប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េក៏ដោយ
- ក្នុងករណីពិនិត្យឃើញមានសារធាតុញៀនក្នុងខ្លួន នោះបេក្ខជននឹងត្រូវបញ្ជូនត្រឡប់មកកម្ពុជាវិញ ទោះជាបានចូលក្នុងសាធារណរដ្ឋកូរ៉េហើយក៏ដោយ
- យោងអនុស្សរណៈយោគយល់ស្តីពីការបញ្ជូនពលករ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS មានតែគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសតែមួយប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ មានតែបេក្ខជនដែលបានប្រឡងជាប់ និងបានចុះឈ្មោះចូលក្នុងបញ្ជីស្វែងរកការងារធ្វើតាមរយៈ គ.ប.ប.ព.ប ប៉ុណ្ណោះ ដែលអាចត្រូវបានជ្រើសរើសដោយនិយោជកកូរ៉េតាមរយៈប្រព័ន្ធកុំព្យូទ័រ។ ភ្នាក់ងារឯកជនណាមួយដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការបញ្ជូនពលករនឹងត្រូវធ្វើការផាកពិន័យតាមច្បាប់ជាធរមាន
- ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េនេះរៀបចំដោយ ក្រសួងមុខរបរ និងការងារ នៃសាធារណរដ្ឋកូរ៉េ និងអនុវត្តដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ដោយមានការសហការជាមួយគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ដែលមានទីតាំងអគារលេខ៨ ក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០១២-២៥៣-៥៥៥ / និង០១១-៣៨៣-៧៥៥ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងមហាផ្ទៃ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីជ្រាប"
-រដ្ឋបាលរាជធានី ខេត្ត "ដើម្បីជ្រាប និងសហការ"
-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
-ឯកសារ កាលប្បវត្តិ